# ការងារ ១០ឆ្នាំ នៅវិទ្យាស្ថាន CDRI នៅកម្ពុជា – ការពិចារណាផ្ទាល់ខ្លួនលើបទពិសោធន៍នេះ

## សេចក្ដីផ្ដើម៖ ការរក្សាតុល្យភាពរវាងលក្ខណៈឯករាជ្យ នឹងការចូលពាក់ព័ន្ធ

អស់រយៈពេលជាង១០ឆ្នាំ ក្នុងដំណែងជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI ខ្ញុំបានទទួលការអញ្ជើញជាច្រើនលើកទាំងនៅកម្ពុជា និងប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ី ឲ្យធ្វើបទបង្ហាញស្ដីពី ប្រទេសកម្ពុជា និងការអភិវឌ្ឍ។ ជារឿយៗខ្ញុំចាប់ផ្ដើមបទបង្ហាញដោយនិយាយថា "ក្នុងការសិក្សាអន្តរជាតិស្ដីអភិវឌ្ឍន៍ គេតែងពណ៌នាកម្ពុជាថាជា ប្រទេសលូតលាស់តិចជាងគេទើបបញ្ចប់ទំនាស់ និងពឹងផ្អែកលើជំនួយ ដែលសុទ្ធតែជាការវាយតម្លៃអវិជ្ជមាន។ តទៅនេះ ខ្ញុំសូមបង្ហាញពីរូបភាពមានតុល្យភាពល្អគួរសមមួយ នៃសមិទ្ធផលអភិវឌ្ឍន៍គួរឲ្យកត់សំគាល់របស់កម្ពុជាក្នុងសម័យថ្មី ក្រោយពេលទទួលបានសន្តិភាព និងស្ថិរភាពក្នុងឆ្នាំ១៩៩៨ ព្រមទាំងបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ។" ការតាំងចិត្តធ្វើការស្រាវជ្រាវមានការថ្លឹងថ្លែងល្អផ្អែកលើភស្តុតាង មានការវិភាគត្រឹមត្រូវ និងមានការចូលរួមជាលក្ខណៈកសាង បានកំណត់នូវវិធីសាស្ត្ររបស់ខ្ញុំ ក្នុងការដឹកនាំ CDRI ។

វិធីសាស្ត្រនេះ បានទទួលការបញ្ជាក់គាំទ្រពីការវាយតម្លៃដោយឯករាជ្យ អនុវត្តឡើងដោយក្រុមទីប្រឹក្សានៃទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) សម្រាប់ការត្រួតពិនិត្យពាក់កណ្ដាលអាណត្តិលើកម្មវិធីរយៈពេលប្រាំឆ្នាំ (២០១១-១៦) នៃជំនួយទ្រទ្រង់ និងភាពជាដៃគូជាមួយវិទ្យាស្ថាន CDRI (www.sida.se/publications)។ លទ្ធផលរកឃើញដ៏សំខាន់មួយផ្អែកលើការវាយតម្លៃពីផលិតផល សកម្មភាព និងប្រព័ន្ធស្រាវជ្រាវផ្នែកគោលនយោបាយរបស់ CDRI និងបទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធ ២៥រូប មកពីជួររដ្ឋាភិបាល ដៃគូអភិវឌ្ឍ មជ្ឈដ្ឋានសិក្សា សហគមន៍ស្រាវជ្រាវ វិស័យឯកជន និង សង្គមស៊ីវិលបង្ហាញថា CDRI "រក្សាបានល្អនូវតុល្យភាពរវាងឯករាជ្យ នឹងការចូលរួមពាក់ព័ន្ធ" ហើយគេមើលឃើញ CDRI ជាតួអង្គដ៏សំខាន់ក្នុងការជជែកវែកញែកផ្នែកគោលនយោបាយ ក្នុងបរិយាកាសនយោបាយមួយដ៏ស្មុគស្មាញ។ គេបានរកឃើញ ដូច្នេះ ទាំងនៅក្នុងផលិតផលស្រាវជ្រាវ វេទិកាសាធារណៈ និងក្នុងកិច្ចសន្ទនាជាមួយរដ្ឋាភិបាល និងអ្នកមានឥទ្ធិពលនានាដែលជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រទេសកម្ពុជា។

ពិនិត្យលើ បទពិសោធន៍មួយទសវត្សរ៍កន្លងទៅរបស់រូបខ្ញុំជាមួយ CDRI គឺមាន ៣ចំណុច លេចធ្លោជាងគេ៖ (១) ល្បឿននៃកំណើន និងការផ្លាស់ប្ដូរសម្រាប់ទាំងកម្ពុជា និង CDRI, (២) បទសោធន៍សំខាន់ៗមួយចំនួនអំពី ភាពជាដៃគូពិតៗ, ការកសាងសមត្ថភាពស្ថាប័នពិតៗ និងសង្គមស៊ីវិលពិតៗ និង (៣) បែបទដែលទិដ្ឋភាពនៃការអភិវឌ្ឍបច្ចុប្បន្ន និងទៅអនាគតរបស់ CDRI ត្រូវជាប់ពាក់ព័ន្ធកាត់មិនដាច់ជាមួយតំបន់ជុំវិញពោលគឺ មហាអនុតំបន់មេគង្គ អាស៊ាន អាស៊ីខាងកើត និងតំបន់ក្រៅពីនេះទៀត។

## កំណើន និងការផ្លាស់ប្ដូរក្នុងមួយទសវត្សរ៍ —សម្រាប់កម្ពុជា និងសម្រាប់ CDRI

ក្នុងរយៈមួយទសវត្សរ៍ពីឆ្នាំ២០០៤ ដល់ ២០១៤ មានការផ្លាស់ប្ដូរគួរឲ្យកត់សំគាល់ ទាំងនៅកម្ពុជា និងនៅ CDRI។ ក្នុងពិធីអបអរសាទរការផ្ទេរតំណែងថ្នាក់ដឹកនាំរបស់ CDRI ក្នុងខែកញ្ញាកន្លងទៅ ខ្ញុំបានរំលឹកដល់អ្នករួមការងារអំពីសមិទ្ធផលដែលយើងសម្រេចបានរួមគ្នា។ បុគ្គលិក CDRI បានកើនពី ៦៥ ដល់ ៨៥នាក់, ថវិកាសម្រាប់ប្រតិបត្តិការប្រចាំឆ្នាំកើនពី ១,៥លាន ដល់ ២,៥លានដុល្លារ ហើយបុគ្គលិកផ្នែកស្រាវជ្រាវកើនពី ២០ ដល់ ៤៥នាក់ ក្នុងនោះអ្នកស្រាវជ្រាវសញ្ញាតិកម្ពុជាបានបញ្ចប់ថ្នាក់បណ្ឌិត កើនពី ០ ដល់ ៧នាក់ និងកំពុងបន្តកើនឡើងទៀត។ CDRI បានរៀបចំ កម្មវិធីស្រាវជ្រាវរបស់ខ្លួនជាថ្មី ដើម្បីឆ្លុះបញ្ចាំងពី វិស័យអភិវឌ្ឍន៍ជាអាទិភាពចម្បងៗប្រាំរបស់កម្ពុជា ដោយមានអ្នកស្រាវជ្រាវជាន់ខ្ពស់សញ្ញាតិកម្ពុជា បំពេញតួនាទីជាអ្នកសម្របសម្រួលក្នុងកម្មវិធីនីមួយៗ។ យើងបានចេញផ្សាយរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ក្នុងទម្រង់មួយងាយស្រួលប្រើ ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវសំខាន់ៗមួយចំនួន របស់ CDRI ដែលជាប់ពាក់ព័ន្ធខ្លាំងទៅនឹងគោលនយោបាយ។ យើងបានចាប់ដៃគូជាមួយធនាគារ ANZ Royal ផ្ដួចផ្ដើមគំនិតធ្វើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំ ដែលមានអ្នកចូលរួមកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់សន្និសីទលើកទី៩ នេះ។

វិទ្យាស្ថាន CDRI ទទួលបានជំនួយទ្រទ្រង់កាន់តែរឹងមាំពីដៃគូចម្បងរបស់ខ្លួន គឺ ទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិស៊ុយអែត (Sida) ដែលមានតាំងពី កម្មវិធីទ្រទ្រង់រយៈពេលបីឆ្នាំ លើចំណាយប្រតិបត្តិការ និង ការងារផ្នែកអភិបាលកិច្ចជាពិសេស កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, រហូតដល់កម្មវិធីទ្រទ្រង់ធំទូលាយរយៈពេលប្រាំឆ្នាំ ក៏ដូចជា មូលនិធិសម្រាប់បញ្ហាសំខាន់ៗទើបផុសឡើងថ្មី ដូចជា កំណើនសម្រាប់គ្រប់គ្នា ការអប់រំ និង ការប្រែប្រួលអាកាសធាតុ ជាដើម។ ដោយមានជំនួយទ្រទ្រង់រឹងមាំពីសំណាក់ មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា យើងបានផ្ដួចផ្ដើមបង្កើតវេទិកាស្រាវជ្រាវអភិវឌ្ឍន៍ (DRF) នៅកម្ពុជា ដែលជាកិច្ចសហការរវាងស្ថាប័នស្រាវជ្រាវឈានមុខ រួមមាន CDRI សកលវិទ្យាល័យភូមិន្ទភ្នំពេញ សកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានស្រាវជ្រាវ និងបណ្ដុះបណ្ដាល វិទ្យាស្ថានជាតិសុខភាពសាធារណៈ និង

---

អត្ថបទនេះ រៀបរៀងដោយ Larry Strange ជាទីប្រឹក្សាជាន់ខ្ពស់នៃវិទ្យាស្ថាន CDRI ។ សូមយោងអត្ថបទនេះថា L. Strange. 2015. "My Decade with CDRI – A Personal Reflection." *Cambodia Development Review* 18(4): 12-16.

សមាគមសេដ្ឋកិច្ចកម្ពុជា។ វេទិកានេះមាន ក្រុមចំណាប់អារម្មណ៍ស្រាវជ្រាវតាមប្រធានបទចំនួន ៦ ដោយក្រុមនីមួយៗដឹកនាំដោយសមាជិកដៃគូមួយនៃ DRF និងមានធ្វើសន្និសីទប្រចាំឆ្នាំ និងវេទិកា ICT ដើម្បីផ្ដល់ឱកាសឲ្យអ្នកស្រាវជ្រាវវ័យក្មេងអាចចែករំលែកចំណេះដឹង និងបទពិសោធន៍គ្នាទៅវិញទៅមក និងកសាងសមត្ថភាពស្រាវជ្រាវរបស់ខ្លួន។

ដោយមានជំនួយទ្រទ្រង់ពី IDRC និង មូលនិធិ Rockefeller នោះ វិទ្យាស្ថាន CDRI បានពង្រឹង បណ្ដាញវិភាគអភិវឌ្ឍន៍សហការគ្នាក្នុងតំបន់ ដើម្បីបង្កើតភាពជាដៃគូធំទូលាយក្នុងមហាអនុតំបន់មេគង្គ (GMS) ដែលមានសមាជិកជា ស្ថាប័នស្រាវជ្រាវឈានមុខមកពីប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និង ខេត្តយុនណាន នៃប្រទេសចិន និងមានការងារផ្ដោតលើបញ្ហាសំខាន់ៗដូចជា កំណើនសម្រាប់គ្រប់គ្នាក្នុង GMS ជាដើម។ ដោយមើលឃើញពីសារៈសំខាន់ នៃសមាហរណកម្ម និង សហប្រតិបត្តិការក្នុងតំបន់ សម្រាប់អនាគតប្រទេសកម្ពុជានោះ យើងបានខិតខំជំរុញ CDRI ឲ្យក្លាយជាវិទ្យាស្ថានថ្នាក់តំបន់មួយដែលដើរតួនាទីសកម្ម ក្នុងបណ្ដាញស្រាវជ្រាវក្នុងតំបន់ តាមរយៈវេទិកា និងដៃគូនានាផ្នែកគោលនយោបាយអភិវឌ្ឍន៍។

## ដៃគូពិតៗ ការកសាងសមត្ថភាពពិតៗ សង្គមស៊ីវិលពិតៗ

ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព និងការកសាងសមត្ថភាពស្ថាប័នក្នុងរយៈពេលវែង សំខាន់ខ្លាំងណាស់ដើម្បីឲ្យ CDRI អាចសម្រេចតាមគោលដៅរបស់ខ្លួន។ ក្នុងការងារមួយទសវត្សរ៍នៅ CDRI ខ្ញុំអាចសន្និដ្ឋានបានថា ពាក្យពីរដែលឃើញប្រើខុសញឹកញាប់ជាងគេ នៅក្នុងកម្រងពាក្យនៃការអភិវឌ្ឍក្នុងតំបន់ គឺ "ដៃគូ" ឬ "ភាពជាដៃគូ", និង "ការកសាងសមត្ថភាព" ឬ "ការអភិវឌ្ឍសមត្ថភាព"។ ហេតុអ្វីបានជាខ្ញុំសន្និដ្ឋានដូច្នេះ និងហេតុអ្វីបានជាខ្ញុំតែងលើកពីចំណុចនេះ នៅតាមវេទិកាផ្សេងៗនៅក្នុងតំបន់ និងអន្តរជាតិ?

ខ្ញុំជឿថា ក្នុងចំណោមជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស (ODA) ផ្ដល់ទៅឲ្យ ប្រទេសលូតលាស់តិចជាងគេនៅក្នុងតំបន់យើងនេះ មានភាគច្រើនពេកដែលជំរុញឡើងដោយផ្នែកផ្គត់ផ្គង់ មិនមែនដោយផ្នែកតម្រូវការនោះទេ ហើយមិនសូវឆ្លុះបញ្ចាំងពីគំនិតផ្ដួចផ្ដើម និងភាពជាម្ចាស់នៃប្រជាជនក្នុងស្រុកឡើយ។ រយៈពេលខ្លីនៃការសន្យាផ្ដល់ និងការផ្ដល់ ODA ព្រមទាំងការរចនារៀបចំកម្មវិធីពាក់ព័ន្ធតាមប្រទេសនីមួយៗ នៅតែជាកត្តារាំងដល់ការផ្ដល់ និងប្រសិទ្ធភាពជំនួយ ហើយជារឿយៗណាស់ ក៏ឃើញមានការខកខាន ឬអសមត្ថភាពក្នុងការធ្វើវិនិយោគរយៈពេលវែងទៅលើការពង្រឹងស្ថាប័នក្នុងស្រុក និងការលំអៀងទៅតាមមនោគមវិជ្ជា និងប្រភេទស្ថាប័ន ដែលត្រូវផ្ដល់វិនិយោគធំៗទៅឲ្យ។

បញ្ហាជាច្រើនក្នុងការគ្រប់គ្រង និងសម្របសម្រួលជំនួយដែលប្រទេសលូតលាស់តិចជាងគេត្រូវប្រឈមមុខ វាផុសចេញពីលក្ខណៈដែល សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ គឺជាឧស្សាហកម្មមួយយ៉ាងធំដល់រាប់ពាន់លានដុល្លារ និងមានអំណាចខ្លាំងណាស់។ រហូតមកដល់ពេលថ្មីៗ ផ្នែកផ្ដល់ជំនួយនេះស្ថិតក្រោមការគ្រប់ដណ្ដប់នៃប្រទេសអភិវឌ្ឍន៍ ឬទីភ្នាក់ងារអភិវឌ្ឍន៍ពហុភាគី ដែលពួកគេត្រួតត្រា ឬទីភ្នាក់ងារទ្វេភាគីរបស់ពួកគេ ឬបណ្ដាក្រុមហ៊ុនផ្ដល់ការប្រឹក្សា ឬពួកទីប្រឹក្សាដែលមានច្រើននាក់ ជាអតីតបុគ្គលិកនៃទីភ្នាក់ងារអភិវឌ្ឍន៍ទាំងនោះ ឬផ្នែកផ្ដល់មតិប្រឹក្សានៃសកលវិទ្យាល័យ និងស្ថាប័នសិក្សាស្រាវជ្រាវនានា ដែលកំពុងប្រឈមមុខនឹងតម្រូវការបង្កើតប្រាក់ចំណូល។ ឧស្សាហកម្មអភិវឌ្ឍន៍នេះ នៅពេលដែលគោលនយោបាយ និងចំណូលចិត្តក្នុងការអភិវឌ្ឍអន្តរជាតិមានការផ្លាស់ប្ដូរ ក៏បង្កើតចេញជាអនុឧស្សាហកម្មមានប្រាក់ចំណេញខ្ពស់ដែលក្នុងពីរទសវត្សរ៍កន្លងទៅនេះ មានដូចជា ផ្នែកអភិបាលកិច្ចយេនឌ័រ ការកសាងសមត្ថភាព ហើយថ្មីៗបំផុតនេះ គឺផ្នែកប្រសិទ្ធភាពជំនួយ។

## ដៃគូអភិវឌ្ឍន៍ពិតៗ

ក្នុងមួយទសវត្សរ៍កន្លងទៅនេះ CDRI មានកិច្ចសហការល្អខាងផ្នែកគម្រោងស្រាវជ្រាវ និងធនធានជាមួយដៃគូពហុភាគី និងទ្វេភាគីភាគច្រើន ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ប៉ុន្តែមាន ២ស្ថាប័នដែលជាដៃគូអភិវឌ្ឍន៍ពិតៗ បានជួយទ្រទ្រង់ខ្លាំងក្លាដល់គោលដៅ និងសកម្មភាព CDRI គឺមាន Sida និង IDRC។ Sida បានសហការជាមួយ CDRI តាំងពីដើមទីក្នុងប្រវត្តិវិទ្យាស្ថាន ហើយបានពង្រឹងជំនួយទ្រទ្រង់ពីមួយឆ្នាំទៅមួយឆ្នាំ រហូតក្លាយជាដៃគូរយៈពេលវែងសំខាន់ជាងគេរបស់ CDRI នាបច្ចុប្បន្ន។ កម្មវិធីជំនួយទ្រទ្រង់រយៈពេល ៥ឆ្នាំ របស់ Sida សម្រាប់ចំណាយប្រតិបត្តិការស្នូល អាចជួយ CDRI ឲ្យសម្រេចបាននូវស្តង់ដាខ្ពស់ផ្នែកអភិបាលកិច្ច, ការពង្រឹងស្ថាប័ន និងប្រព័ន្ធប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក៏ដូចជា ធ្វើការស្រាវជ្រាវមានគុណភាពខ្ពស់ផ្នែកអភិបាលកិច្ច កំណែទម្រង់វិស័យសាធារណៈ កំណើនសម្រាប់គ្រប់គ្នា ការអប់រំ ជំនាញនិងការងារ និង ការប្រែប្រួលអាកាសធាតុ។

IDRC បានផ្ដល់ជំនួយទ្រទ្រង់រយៈពេលមធ្យម និងវែងដ៏មានតម្លៃ សម្រាប់បណ្ដាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS-DAN) របស់ CDRI, វេទិកាស្រាវជ្រាវអភិវឌ្ឍន៍ជំហានទី១ និងទី២, និង កម្មវិធីថ្មីស្ដីពី ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចធនធានទឹកនៅកម្ពុជា ដែលជាកិច្ចសហការរវាង CDRI នឹង ក្រសួងធនធានទឹកនិងឧតុនិយម អាជ្ញាធរទន្លេសាប វិទ្យាស្ថានបច្ចេកទេសនៃកម្ពុជា និង សកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ដៃគូពិតៗទាំងពីរ បង្ហាញជានិច្ចនូវការគោរពដល់គំនិតផ្ដួចផ្ដើម និងភាពជាម្ចាស់នៃស្ថាប័នក្នុងស្រុក, តម្លៃនៃវិនិយោគរយៈពេលមធ្យម និងរយៈពេលវែងទៅលើស្ថាប័នក្នុងស្រុក, ការអភិវឌ្ឍកម្មវិធីជំរុញឡើងដោយតម្រូវការ ជាជាងការផ្គត់ផ្គង់, ព្រមទាំង តម្លាភាព និងគណនេយ្យភាពទៅវិញទៅមក។

## ការកសាងសមត្ថភាពពិតៗ

គ្មានលស់ថ្ងៃទេ ក្នុងបន្ទប់ទទួលភ្ញៀវនៅតាមសណ្ឋាគារនានានៅក្រុងភ្នំពេញ មានសញ្ញាបង្ហាញផ្លូវអ្នកចូលរួមទៅកាន់

បន្ទប់សិក្ខាសាលា និងការប្រជុំផ្សេងៗស្តីពីការអភិវឌ្ឍ។ កម្មវិធីទាំងនេះជាច្រើន សុទ្ធតែផ្សព្វផ្សាយថាជា "ការកសាងសមត្ថភាព" ប៉ុន្តែតាមពិតជា វគ្គបណ្តុះបណ្តាលរយៈពេលខ្លី ឬជាសកម្មភាពបំផុសការយល់ដឹង ហើយខ្លះក៏មានប្រយោជន៍ និងខ្លះក៏គ្មានប្រយោជន៍ទេ។ បទពិសោធន៍នៅ CDRI បានបង្រៀនយើងថា ការកសាង ឬការអភិវឌ្ឍសមត្ថភាពស្ថាប័នប្រកបដោយប្រសិទ្ធភាព ជាពិសេសសម្រាប់ស្ថាប័នស្រាវជ្រាវ ត្រូវមានការគួបផ្សំគ្នានូវការវិភាគពីតម្រូវការស្ថាប័ន, ការរៀបចំឡើងវិញ និងការពង្រឹងស្ថាប័ន, ការបង្កើនគុណសម្បត្តិផ្នែកអប់រំ និងជំនាញវិជ្ជាជីវៈតាមរយៈការអប់រំក្រោយថ្នាក់ឧត្តម, កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍវិជ្ជាជីវៈ, ការផ្តល់មតិណែនាំផ្នែកជំនាញបច្ចេកទេស និងការផ្ទេរជំនាញ ក៏ដូចជា កិច្ចសហការជាលក្ខណៈស្ថាប័នធ្វើការផ្លាស់ប្តូរគ្នានូវបុគ្គលិក និងអ្នកហាត់ការ។ ក្នុងបរិបទកម្ពុជា ការកសាងសមត្ថភាពអាចមានប្រសិទ្ធភាពខ្ពស់បំផុត នៅពេលមានកិច្ចសហការជាលក្ខណៈស្ថាប័នរយៈពេលវែង រវាងស្ថាប័នស្រាវជ្រាវទន់ខ្សោយ នឹងស្ថាប័នខ្លាំងៗ ជាពិសេសនៅតាមប្រទេសក្នុងតំបន់ (ប្រទេសអាស៊ាន, ចិន, កូរ៉េខាងត្បូង, ជប៉ុន) ដែលត្រូវមានទំនាក់ទំនងអភិវឌ្ឍន៍ និងសេដ្ឋកិច្ចរយៈពេលវែងជាមួយកម្ពុជា។ ការពឹងផ្អែកខ្លាំងពេកលើទីប្រឹក្សាបច្ចេកទេស និងទីប្រឹក្សាអន្តរជាតិមានតម្លៃខ្ពស់ៗ ហើយនិងការធ្វើវិនិយោគរយៈពេលខ្លីជារឿយៗ ជាជាងការធ្វើវិនិយោគរយៈពេលវែងក្នុងការកសាងសមត្ថភាព និងភាពជាម្ចាស់ក្នុងស្រុក វាជាការយកសមត្ថភាពមកជំនួស មិនមែនការអភិវឌ្ឍសមត្ថភាពទេ ហើយត្រូវពឹងផ្អែកលើគេកាន់តែយូរទៀត។ ការកសាងសមត្ថភាពស្ថាប័នពិតៗ ទាមទារការប្រឹងប្រែងជាខ្លាំងទាំងពីថ្នាក់គ្រប់គ្រង និងបុគ្គលិក។ គេពិបាករចនារៀបចំវាឲ្យមានប្រសិទ្ធភាព ហើយផ្ទៃក្នុងអង្គភាព ក៏ត្រូវប្រឹងជំរុញ និងតាំងខ្លួនជាម្ចាស់វាដែរ។ តាមធម្មតា វាទាមទារនូវសមត្ថភាពជំនាញទាំងនៅខាងក្នុង និងមកពីខាងក្រៅ។ វាមានតម្លៃខ្ពស់ ហើយត្រូវចំណាយពេលច្រើន។ ការកសាងសមត្ថភាពពុំមានទីបញ្ចប់ឡើយ ពីព្រោះបរិស្ថានជុំវិញស្ថាប័ន និងតម្រូវការរបស់អតិថិជនផ្លាស់ប្តូរឥតឈប់។

## ឈានទៅកាន់សង្គមស៊ីវិលពិតៗនៅកម្ពុជា

ក្នុងឆ្នាំ២០១៣ អ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI បានចេញផ្សាយឯកសារពីរ ដែលមានលក្ខណៈចម្រូងចម្រាស់ គឺ *NGOs និងក្តីស្រមៃពីសង្គមស៊ីវិលនៅកម្ពុជា* និង *២០ឆ្នាំធ្វើការពង្រឹងសង្គមស៊ីវិលនៅកម្ពុជា៖ ដល់ពេលត្រូវបូកសរុបឡើងវិញ* (Ou and Kim 2013a, b)។ ឯកសារទាំងពីរបានលើកនូវបញ្ហាគោលនយោបាយសាធារណៈសំខាន់ៗ ស្តីពី តួនាទី គុណភាព និងអភិបាលកិច្ចនៃសហគមន៍ NGO ដ៏ធំទូលាយ និងខុសៗគ្នានៅកម្ពុជា និងភាពក្មេងខ្ចីនៃសង្គមស៊ីវិលពិតៗ។ ទោះបីមានជំនួយទ្រទ្រង់ហិរញ្ញវត្ថុធំដុំពីអន្តរជាតិ ជាច្រើនទសវត្សរ៍មកហើយក្តី។ ក្នុងមួយទសវត្សរ៍កន្លងទៅនេះ ខ្ញុំកាន់តែបារម្ភខ្លាំងឡើងពីគុណភាព និងប្រសិទ្ធភាពមិនស្មើគ្នានៃ NGOs នៅកម្ពុជា។ NGOs មានច្រើន និងទទួលបានជំនួយទ្រទ្រង់ហិរញ្ញវត្ថុច្រើនៗ ក៏ពិតមែន ប៉ុន្តែជារឿយៗពួកគេនៅមានយន្តការត្រួតពិនិត្យ និងវាយតម្លៃអន់ខ្សោយ ឬគ្មានសោះតែម្តង ខ្វះខាតការយល់ដឹង និងការប្តេជ្ញាចិត្តអនុវត្តតាមស្តង់ដាអភិបាលកិច្ចកម្រិតខ្ពស់ ក្នុងអង្គការរបស់ខ្លួន ទោះបីតែងណែនាំជាសាធារណៈលើចំណុចទាំងនេះដល់អង្គការឯទៀតក្តី។

ខ្ញុំចាប់ផ្តើមបម្រើការនៅកម្ពុជា បន្ទាប់ពីបានបញ្ចប់អាជីពវិជ្ជាជីវៈនៅប្រទេសអូស្ត្រាលី ដែលរួមមានការចូលរួមសំខាន់ៗក្នុងបណ្តាញ និងអង្គការសង្គមស៊ីវិលឈានមុខនានា ក្នុងឋានៈជាអ្នកតស៊ូមតិគាំទ្រសហជីពពលករឧស្សាហកម្ម, ជាបុគ្គលិកបន្ទាប់មកជាសមាជិកក្រុមប្រឹក្សាភិបាល ហើយក្រោយមកទៀតជាប្រធានក្រុមប្រឹក្សាភិបាល នៃមជ្ឈមណ្ឌលតស៊ូមតិដើម្បីផលប្រយោជន៍សាធារណៈ (Public Interest Advocacy Centre) ដែលជាមជ្ឈមណ្ឌលផ្នែកច្បាប់ បម្រើផលប្រយោជន៍សាធារណៈឈានមុខនៅអូស្ត្រាលី, ជាបេក្ខជនរបស់សមាគមអ្នកប្រើប្រាស់អូស្ត្រាលី សម្រាប់ការតែងតាំងក្នុងគណៈកម្មការផ្តល់អាជ្ញាប័ណ្ណ NGO (ក្រោយមកទៀតប្តូរឈ្មោះថា ក្រុមប្រឹក្សាអូស្ត្រាលីដើម្បីជំនួយក្រៅប្រទេសៈ ACFOA) ដែលជាអង្គការកំពូលសម្រាប់ពួក NGO ជាប់ពាក់ព័ន្ធនឹងជំនួយអន្តរជាតិ នៅប្រទេសអូស្ត្រាលី។

តាមប្រវត្តិដូចខាងលើ ខ្ញុំរីករាយណាស់ដោយបានចូលបម្រើការមួយអាណត្តិក្នុង គណៈកម្មការផ្តល់អាជ្ញាប័ណ្ណ NGO នៃកម្មវិធីរបៀបអនុវត្តល្អសម្រាប់ NGO (NGO-GPP) នៃគណៈកម្មការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលជាយន្តការដ៏សំខាន់មួយគ្រប់គ្រង និងជំរុញឡើងដោយបណ្តាស្ថាប័នក្នុងស្រុក ដើម្បីលើកកម្ពស់អភិបាលកិច្ច តម្លាភាព និងគណនេយ្យភាពក្នុងសហគមន៍ NGO។ បទពិសោធន៍នេះជួយឲ្យខ្ញុំបានឃើញនូវសេវាប្រកបដោយគុណភាព ផ្តល់ឲ្យដោយ NGOs ជាតិ និងអន្តរជាតិជាច្រើននៅកម្ពុជា និងអង្គភាពកំពូលរបស់ពួកគេ ដូចជា វេទិកា NGO និង CCC ដែលដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍវិស័យសុខភាព អប់រំ ការអភិវឌ្ឍស្ត្រីនិងយុវជន ការអភិវឌ្ឍសហគមន៍ មីក្រូហិរញ្ញវត្ថុ ការត្រួតពិនិត្យការបោះឆ្នោត និងវិស័យផ្សេងៗទៀត។ ពួកគេក៏បានបង្ហាញការប្តេជ្ញាចិត្តសម្រេចឲ្យបាននូវអភិបាលកិច្ចល្អ និងការចូលរួមបែបស្ថាបនាផ្នែកគោលនយោបាយជាមួយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍ស្រាវជ្រាវដែរ។ ខ្ញុំសូមលើកទឹកចិត្តអ្នកដទៃទៀតដែលមិនទាន់មានការចាស់ចិត្តចាស់គំនិតដល់កម្រិតនេះឲ្យ "អនុវត្តដូចអ្វីដែលខ្លួនបានទូន្មានគេ" ក្នុងការលើកកម្ពស់អភិបាលកិច្ច តម្លាភាព និងគណនេយ្យភាព, ការចូលរួមប្រកបដោយទំនួលខុសត្រូវ, និងការប្រើប្រាស់ភស្តុតាងផ្អែកលើការស្រាវជ្រាវ, សម្រាប់ធ្វើការតស៊ូមតិ និងសកម្មភាពកែប្រែសង្គមផ្សេងៗ។

## លំនាំការអភិវឌ្ឍនៅកម្ពុជា និងតំបន់ជុំវិញ៖ តើមានអ្នកផ្លាស់ប្តូរស្ថានភារណ៍ខ្លះទេ?

មុនពេលខ្ញុំមកបម្រើការនៅ CDRI និងកម្ពុជា ខ្ញុំបានបំពេញការងារ ១០ឆ្នាំ ជានាយកវិទ្យាស្ថានអាស៊ី-អូស្ត្រាលី ដែលជាក្រុមផ្តល់គំនិតឯករាជ្យមួយផ្តោតការងារលើ នយោបាយក្រៅប្រទេសរបស់អូស្ត្រាលី សមាហរណកម្មក្នុងតំបន់ និង និន្នាការភូមិសាស្ត្រនយោបាយសំខាន់ៗនៅអាស៊ីខាងកើត, ដោយមានបណ្តាញជា

បណ្តាស្ថាប័នស្រាវជ្រាវឈានមុខផ្នែកគោលនយោបាយ នៅក្នុងតំបន់។ នៅពេលរូបខ្ញុំទទួលការតែងតាំង ក្រុមប្រឹក្សាភិបាល CDRI បានលើកទឹកចិត្តខ្ញុំឲ្យប្រើប្រាស់ប្រវត្តិការងារនេះ ដើម្បីជំរុញឲ្យ CDRI មានស្ថានភាពកាន់តែយុទ្ធសាស្ត្រឡើង ក្នុងឋានៈជាស្ថាប័នស្រាវជ្រាវផ្នែកគោលនយោបាយ ទាំងនៅក្នុងស្រុក និងក្នុងតំបន់។

ជាលទ្ធផល ក្នុងមួយទសវត្សរ៍កន្លងទៅនេះ យើងបានបង្កើតកិច្ចសហការគួរជាទីគាប់ចិត្តបំផុតជាមួយ វិទ្យាស្ថាននានានៃបណ្ឌិតសភាផ្នែកវិទ្យាសាស្ត្រសង្គមនៃប្រទេសចិន (CASS), វេទិកាវិទ្យាស្ថាននៅអាស៊ីបូព៌ា នៃវិទ្យាស្ថានកូរ៉េសម្រាប់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ (KIEP), បណ្តាញអភិវឌ្ឍន៍អាស៊ីបូព៌ានៃធនាគារពិភពលោក (EADN), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), និង បណ្តាញក្រុមផ្តល់គំនិតខាងការអភិវឌ្ឍក្នុងតំបន់នៃវិទ្យាស្ថាន ADB, បណ្តាញស្រាវជ្រាវនិងបណ្តុះបណ្តាលផ្នែកពាណិជ្ជកម្មនៅតំបន់អាស៊ីប៉ាស៊ីហ្វិក (ARTNeT) នៃគណៈកម្មាធិការសង្គម និងសេដ្ឋកិច្ចសហប្រជាជាតិសម្រាប់តំបន់អាស៊ីនិងអាស៊ីប៉ាស៊ីហ្វិក (UNESCAP) និង វិទ្យាស្ថានសិក្សាពីតំបន់អាស៊ីអាគ្នេយ៍ (SEAS) នៃប្រទេសសិង្ហបុរី។ យើងក៏បានគាំទ្រយ៉ាងសកម្មដល់ការបង្កើត និងការចាប់ដៃគូជាមួយវិទ្យាស្ថានធនធានអភិវឌ្ឍន៍មីយ៉ាន់ម៉ា (MDRI) ដែរ។

ការក្តាប់យកបានស្ថានភាពនេះ ជួយឲ្យយើងសម្រេចគោលដៅនៃការជំរុញ CDRI ឲ្យមានវត្តមាននៅតុប្រជុំពិភាក្សាពីការស្រាវជ្រាវ ផ្នែកគោលនយោបាយសំខាន់ៗ ស្តីពីសហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់អាស៊ី និងផលពាក់ព័ន្ធដល់ការអភិវឌ្ឍសង្គមកិច្ចសេដ្ឋកិច្ចនៅក្នុងតំបន់ និងនៅកម្ពុជាព្រមទាំងដល់អនាគតរួមគ្នានៅក្នុងតំបន់។

នៅឆ្នាំ២០១១ សាស្ត្រាចារ្យ Zhang Yunling នាយកផ្នែកការសិក្សាអន្តរជាតិ នៃ CASS បានអញ្ជើញរូបខ្ញុំឲ្យចូលរួមក្នុងក្រុមជំនាញការថ្នាក់តំបន់មួយ ធ្វើការងារលើគម្រោងដែលគាត់កំពុងដឹកនាំសម្រាប់ វិទ្យាស្ថានស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) ស្តីពី *ការឈានទៅអនុវត្តគំរូអភិវឌ្ឍន៍ថ្មីមួយសម្រាប់អាស៊ីបូព៌ា៖ តួនាទីគោលនយោបាយក្នុងស្រុក និងសហប្រតិបត្តិការក្នុងតំបន់។ ខ្ញុំបានចូលរួមចងក្រងជំពូកមួយ ស្តីពី សេដ្ឋកិច្ចប្រទេសតូចៗមានការអភិវឌ្ឍតិចនៅក្នុងអាស៊ាន៖ តម្រូវការវិធីសាស្ត្រថ្មីមួយ* (Strange 2012)។ ការចូលរួមក្នុងការសិក្សានេះ ជួយឲ្យខ្ញុំអាចប្រមូលនូវគំនិតជាច្រើនដែលខ្ញុំបានយកទៅបង្ហាញនៅក្នុងវេទិកាថ្នាក់ជាតិ និងថ្នាក់តំបន់ ព្រមទាំងក្នុងអត្ថបទមួយចំនួនដែលបានពុម្ពផ្សាយខ្លះ និងមិនបានបោះពុម្ពផ្សាយខ្លះក្នុងមួយទសវត្សរ៍កន្លងទៅនេះ។

សរុបមកខ្ញុំជឿថា ដើម្បីឲ្យកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់កម្ពុជា និងសម្រាប់ប្រទេសកំពុងអភិវឌ្ឍផ្សេងទៀតនៅអាស៊ីបូព៌ាកាន់តែមានប្រសិទ្ធភាព និងសម្រេចបានលទ្ធផលកាន់តែប្រសើរក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គល និងស្ថាប័ននោះ គួរអនុវត្តប្រើវិធីសាស្ត្រកាន់តែធំទូលាយដល់កម្រិតតំបន់ ដោយមានលក្ខណៈដូចខាងក្រោម៖

- ការគោរព និងយល់ដឹងកាន់តែប្រសើរពីតម្រូវការ និងភាពជាម្ចាស់របស់ប្រជាជនស្រុក
- ការកាត់បន្ថយលក្ខខណ្ឌដាក់ចំហ ឬបង្កប់ ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍
- ការផ្តោតលើការកសាងស្ថាប័ន និងអភិវឌ្ឍសមត្ថភាពក្នុងរយៈពេលវែង, ការយល់ដឹងកាន់តែស៊ីជម្រៅពីភាពស្មុគស្មាញនៃយុទ្ធសាស្ត្រទប់ទល់ប្រឆាំងអំពើពុករលួយ នៅក្នុងប្រព័ន្ធផ្សេងៗ និងតួនាទីនៃយុទ្ធសាស្ត្រទាំងនោះក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព
- ការគិតដល់រយៈពេលវែងក្នុងការបង្កើត និងផ្តល់ ODA, តួនាទីកាន់តែសំខាន់នៃភាពជាដៃគូរវាងវិស័យឯកជន នឹងទីភ្នាក់ងារផ្តល់ ODA
- ការគោរពដល់ និងការកេណ្ឌប្រមូល នូវបទពិសោធន៍ និងជំនាញក្នុងស្រុក, ការចែករំលែក និងបង្កើតដំណោះស្រាយ និងគំរូអភិវឌ្ឍន៍ក្នុងតំបន់
- ការបង្កើតកិច្ចសហការជាដៃគូផ្នែកស្ថាប័ន ក្នុងរយៈពេលវែង រវាងរដ្ឋាភិបាល វិស័យឯកជន ស្ថាប័នសិក្សាអប់រំ និងស្រាវជ្រាវពីគោលនយោបាយ និងអង្គការសង្គមស៊ីវិលក្នុងតំបន់អាស៊ីបូព៌ា ដែលសុទ្ធតែជាធាតុផ្សំដ៏មានប្រយោជន៍សម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងតំបន់ និងសម្រាប់សហគមន៍ក្នុងតំបន់នៅថ្ងៃអនាគត។ (Strange 2006)

ទោះបីនៅតំបន់អាស៊ីបូព៌ាសព្វថ្ងៃ កំពុងមានភាពតានតឹងដ៏ស្មុគស្មាញផ្នែកភូមិសាស្ត្រនយោបាយក្តី ក៏ដំណើរការបង្កើត និងអនុវត្ត ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) របស់ ១០ប្រទេសសមាជិកអាស៊ាន បូកនឹងប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន ឥណ្ឌា អូស្ត្រាលី និង ញូហ្ស៊ីលែន (ឬហៅកាត់ថា អាស៊ានបូក៦) បានផ្តល់ជាយានគួរជាទីសង្ឃឹមមួយដើម្បីអនុវត្តវិធីសាស្ត្រកាន់តែធំទូលាយដល់កម្រិតតំបន់ ក្នុងការបង្កើតកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដ៏មានប្រសិទ្ធភាព សម្រាប់កម្ពុជា និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតនៅក្នុងតំបន់។ ក្នុងកិច្ចប្រជុំកំពូលអាស៊ានប្រចាំឆ្នាំ២០១៤ នៅប្រទេសមីយ៉ាន់ម៉ា ថ្នាក់ដឹកនាំប្រទេសអាស៊ានបូក៦ បានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តសម្រេចឲ្យបាននូវកិច្ចព្រមព្រៀង ស្តីពីក្របខ័ណ្ឌ RCEP នៅត្រឹមឆ្នាំ២០១៥ ហើយបន្ទាប់មកឈានទៅអនុវត្តវា ដោយផ្អែកលើបទពិសោធន៍នៃ កិច្ចព្រមព្រៀងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិងសហប្រតិបត្តិការក្នុងតំបន់ ផ្សេងៗទៀត។ RCEP បានទទួលស្គាល់ពីលក្ខណៈខុសៗគ្នានៃប្រទេសជាសមាជិក និងស្ថានភាពពិសេសនៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់មា និងវៀតណាម (CLMV) ដែលត្រូវមានភាពបត់បែនខ្លះក្នុងរបៀបចាត់ចែងជាលក្ខណៈពិសេស និងខុសប្លែកពីគេ មានជាអាទិ៍ ការប្តេជ្ញាញ៉ាំងឲ្យមានសហប្រតិបត្តិការផ្នែកបច្ចេកទេស និងផ្នែកសេដ្ឋកិច្ច ដើម្បីកាត់បន្ថយគម្លាតអភិវឌ្ឍន៍។

នៅឆ្នាំ២០១៤ មិនគ្រាន់តែមានការប្តេជ្ញាចិត្តពីប្រទេសអាស៊ានបូក៦ ញ៉ាំងឲ្យ RCEP ជឿនលឿនទៅមុខប៉ុណ្ណោះទេ

ប៉ុន្តែក៏មានទាំងការវិវត្តសំខាន់ៗផ្សេងទៀត ដែលអាចផ្លាស់ប្តូរស្ថានការណ៍សម្រាប់កម្ពុជា និងគំរូនៃការអភិវឌ្ឍនៅកម្ពុជា។ ការវិវត្តទាំងនេះ រួមមាន ការបង្កើតធនាគារអភិវឌ្ឍន៍ថ្មី ដោយប្រទេស BRICS (ប្រទេសមានសេដ្ឋកិច្ចកំពុងផុសឡើងចម្បងៗទាំងប្រាំ គឺ ប្រេស៊ីល រុស្ស៊ី ឥណ្ឌា ចិន និង អាហ្វ្រិកខាងត្បូង) នៅក្រុងសៀងហៃ និង ធនាគារវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) នៅក្រុងប៉េកាំង ហើយកម្ពុជាក៏បានចុះហត្ថលេខាចូលរួមផងដែរ។ ក្នុងកិច្ចប្រជុំកំពូល GMS ឆ្នាំ២០១៤ លោក ស៊ី យិនពីង ប្រធានាធិបតីប្រទេសចិន បានប្រកាសពីវិនិយោគ និងជំនួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដ៏ធំ ដោយប្រទេសចិនទៅក្នុង ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទំនាក់ទំនងក្នុង GMS ដែលជាប់ទាក់ទងនឹងសមត្ថភាពផលិតកម្ម និងការកាត់បន្ថយភាពក្រីក្រ, និង ទៅក្នុងមូលនិធិ AIIB ថ្មី ដែលជាប់ទាក់ទងនឹងគំនិតផ្តួចផ្តើមផ្លូវសូត្រ (Silk Road) តាមសមុទ្រ និងផ្លូវគោករបស់ចិន។ ទោះបីគំនិតផ្តួចផ្តើម និងធនធានអភិវឌ្ឍន៍ថ្មីៗខ្លះ មិនទាន់មានព័ត៌មានលំអិតច្បាស់លាស់ក្តី ក៏វាទំនងមានផលប៉ះពាល់ខ្លាំង មកលើទិដ្ឋភាពនៃការអភិវឌ្ឍរបស់កម្ពុជា និងប្រទេសជិតខាងកម្ពុជា។

## សិល្បៈ និងជីវិតនៅកម្ពុជា

ការសប្បាយរីករាយដ៏ធំមួយសម្រាប់ខ្ញុំ ក្នុងមួយទសវត្សរ៍កន្លងទៅនេះ គឺ ពិភពសិល្បៈសម័យថ្មីនៅកម្ពុជា ការទិញបានស្នាដៃសិល្បៈកម្ពុជាសម័យថ្មីចម្រុះមួយចំនួន និងចំណងមិត្តភាពជាមួយពួកតារា និងអ្នកសិល្បៈសម័យថ្មីឈានមុខមួយចំនួននៅកម្ពុជា។ នៅខែមេសា ឆ្នាំ២០១៣ ខ្ញុំមានភ័ព្វជា ពិសេសបានចូលរួមព្រឹត្តិការណ៍រយៈពេលមួយសប្តាហ៍ដ៏ចម្បងមួយ នៃមហោស្រពវប្បធម៌ រដូវនៅកម្ពុជា នៅទីក្រុងញូវយកដែលបានប្រមូលផ្តុំសិល្បករសញ្ជាតិកម្ពុជាជាច្រើន ខាងផ្នែកសិល្បៈរូបភាព និងការសម្តែង។ ក្នុងកម្មវិធីរយៈពេល១ខែ គឺមានការសម្តែងការតាំងពិពណ៌ សិក្ខាសាលា និងព្រឹត្តិការណ៍ជាប់ពាក់ព័ន្ធផ្សេងៗដែលផ្តួចផ្តើមឡើង និងសម្របសម្រួលដោយ អង្គការសិល្បៈខ្មែរអមតៈ និងដៃគូនានារបស់អង្គការនេះ។

ក្នុងរយៈពេលតែមួយសប្តាហ៍ ខ្ញុំបានចូលរួមក្នុងការតាំងពិពណ៌ទោល របស់សិល្បករសម័យថ្មីឈានមុខនៅកម្ពុជា គឺ លោក ពេជ្រ សុភាព នៅសារៈមន្ទីរសិល្បៈ Metropolian និងបទសម្ភាសន៍របស់គាត់ ជាមួយលោកប្រធានទទួលបន្ទុកលើវត្ថុតាំងពិពណ៌ ក្នុងសាល Met ដែលមានអ្នកចូលរួមពេញណែន។ ខ្ញុំក៏បានចូលទស្សនា ការសម្តែងរបាំសម័យថ្មីដ៏មានឥទ្ធិពលរបស់ លោកស្រី សុភិលីន ជាម សាពីរោ មានចំណងជើងថា *បត់មួយតាមដងទន្លេ* ក្នុងសាលសម្តែង Joyce Theatre ដែលមានក្រពើយក្សធ្វើពីផ្តៅផលិតដោយលោក ពេជ្រ សុភាព និងសាច់ភ្លេងរបស់អ្នកនិពន្ធបទភ្លេងឈានមុខ គឺ លោក ហ៊ឹម សុភី, និងការពិភាក្សាជាក្រុម រវាងសិល្បករទាំងបីនាក់ ដែលសម្របសម្រួលដោយ អ្នកសិក្សាស្រាវជ្រាវសញ្ជាតិកម្ពុជាកំពុងរស់នៅសហរដ្ឋអាមេរិក នៅចំពោះមុខទស្សនិកជនយ៉ាងច្រើនកុះករពេញក្នុងសាល Asia Society ដ៏ល្បីល្បាញ។

ខ្ញុំជឿថា ជីវិតវប្បធម៌ និងសិល្បៈដ៏រស់រវើកនេះ ជាសូចនាករសំខាន់នៃដំណាក់កាលអភិវឌ្ឍន៍ និងសុខភាពសង្គមរបស់ប្រជាជាតិមួយ។ ខ្ញុំសង្ឃឹមថា សិល្បករកម្ពុជាដ៏ក្លាហានទាំងនេះ និងសិល្បករជំនាន់ក្រោយទើបផុសឡើងថ្មី នឹងទទួលបានការវាយតម្លៃកាន់តែខ្ពស់ និងការគាំទ្រកាន់តែច្រើន នៅពេលកម្ពុជាវិវត្តទៅមុខទៀត។

## សេចក្តីសន្និដ្ឋានៈ ការបន្តដំណែងថ្នាក់ដឹកនាំ CDRI

ខ្ញុំតែងសង្ឃឹមជានិច្ចថា ដល់ពេលសមគួរខ្ញុំត្រូវលាលែងពីដំណែងនោះ នឹងមានជនកម្ពុជាប្រកបដោយគុណសម្បត្តិសមស្របមកបន្តវេន។ នៅពាក់កណ្តាលឆ្នាំ២០១៤ ក្រុមប្រឹក្សាភិបាល CDRI បានតែងតាំងបណ្ឌិត ឆែម រិទ្ធី ដែលជាជនកម្ពុជាដ៏ល្បីល្បាញ និងពេលនោះកំពុងកាន់ដំណែងជានាយកផ្នែកសុខភាពមនុស្ស នៃនាយកដ្ឋានវិទ្យាសាស្ត្របរមាណូ នៃទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ហើយមានបំណងវិលមកបម្រើការងារក្នុងប្រទេសកម្ពុជាវិញនោះ ឲ្យមកបន្តវេនជានាយកប្រតិបត្តិថ្មីរបស់ CDRI ចាប់ពីខែកញ្ញា ឆ្នាំ២០១៤ តទៅ។ ខ្ញុំក៏បានយល់ព្រមដោយរីករាយតាមសំណើរបស់គាត់ ឲ្យរូបខ្ញុំបន្តចូលរួមបម្រើការងារក្នុងដំណែងជាទីប្រឹក្សាជាន់ខ្ពស់នៃ CDRI រហូតដល់ចុងឆ្នាំ២០១៥ ដើម្បីជួយគាំទ្រឲ្យការផ្លាស់ប្តូរថ្នាក់ដឹកនាំមានដំណើររលូនល្អ ព្រមទាំងស្វែងរកឱកាសបម្រើប្រទេសកម្ពុជាតទៅអនាគតទៀត។

ខ្ញុំសូមអរគុណដល់អ្នករួមការងារ សមាជិក និងប្រធានក្រុមប្រឹក្សាភិបាល នាបច្ចុប្បន្ន និងពីអតីតកាល នៅ CDRI ព្រមទាំង ដៃគូ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលជួយឲ្យខ្ញុំបានឆ្លងកាត់បទពិសោធន៍ការងារដ៏តឹងតែង ប៉ុន្តែលើកទឹកចិត្តជាខ្លាំង ធ្វើឲ្យខ្សែជីវិតរបស់ខ្ញុំមានការផ្លាស់ប្តូរយ៉ាងប្រសើរ។ ខ្ញុំសូមជូនពរឲ្យ CDRI បន្តលូតលាស់ និងរីកចម្រើនទៅមុខក្នុងការបម្រើប្រទេសកម្ពុជា និងប្រជាជនកម្ពុជា។

## ឯកសារយោង


Christoplos, Ian, and Karen L. Greene. 2014. *Mid-Term Review of Sweden's Support to the Cambodia Development Resource Institute.* Stockholm: Sida.

Ou Sivhuoch and Kim Sedara. 2013a. *20 Years' Strengthening of Cambodian Civil Society: Time for Reflection.* Working paper Series No. 85. Phnom Penh: CDRI.

Ou Sivhuoch and Kim Sedara. 2013b. "NGOs and the Illusion of a Cambodian Civil Society." *In Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam.* London: Routledge.

Strange, L. 2006. "Development Cooperation for Regional Economic Integration, Prosperity and Community – An East Asian Way Forward?" Paper presented to 2nd East Asian Institutes Forum on *East Asian Economic Integration: Progress and Impediments*, Jeju Island, Philippines, 13 December.

Strange, L. 2012. "ASEAN Small Less Developed Economies: Need for a New Approach." In *Moving Toward a New Development Model for East Asia- The Role of Domestic Policy and Regional Cooperation*, edited by Y. Zhang, F. Kimura and S. Oum, 279-311. ERIA Research Project Report 2011-10, Jakarta: ERIA.